

# លោកយាយកំពូលត្រែះរបស់ខ្ញុំ

Let's Read

The Asia Foundation



លោកយាយរបស់ខ្ញុំចេះសម្តែងត្រែះ។ ខ្ញុំចូលចិត្តលេងជាមួយគាត់។



មិនថាវត្ថុអ្វីឡើយ លោកយាយខ្ញុំអាចយកមកត្រែះបាន ទាំងអស់។ រាល់ពេលគាត់ត្រែះវត្ថុច្រើន មនុស្សនៅជុំវិញគាត់ មានការភ័យខ្លាច។



លោកយាយអាចត្រែះបានគ្រប់ទីកន្លែង ទាំងនៅក្នុងផ្ទះបាយ នៅតាមដងផ្លូវ និងនៅក្នុងផ្សារ។ គ្មាននរណាម្នាក់អាចបញ្ឈប់លោកយាយបានទេ។



លោកយាយបានគ្រែះផ្លែស្វាយឡើងទៅលើ តែចាប់អត់ជាប់ ក៏ធ្លាក់បែកលើដី។ លោកតាពិបាកចិត្តនឹងការគ្រែះវត្ថុរបស់លោកយាយ។



លោកតារកបានដំណោះស្រាយមួយ ដោយគាត់ជូនកូនបាល់ចម្រុះពណ៌ជាកាដូទៅឱ្យលោកយាយ។ លោកយាយរំភើបចិត្តណាស់ ពីព្រោះគាត់បានវត្ថុថ្មីត្រែះលេងទៀតហើយ។



យប់នេះ លោកតាគេងលក់ពេញមួយយប់ ចំណែកលោកយាយត្រែះកូនបាល់ទល់ភ្លឺ។ ខ្ញុំគិតថា លោកយាយរបស់ខ្ញុំជាអ្នកពូកែត្រែះជាងគេ។



ប្អូនៗអ្នកអានជាទីស្រលាញ់!
តើប្អូនធ្លាប់ឃើញគេលេងត្រែះក្នុងការសម្តែងសៀកដែរឬទេ?
តើពួកគេត្រែះអ្វីខ្លះ?
តើប្អូនគិតថាពួកគេអាចត្រែះវត្ថុគ្រប់យ៉ាងដូចលោកយាយ
របស់ខ្ញុំដែរឬទេ?

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*My Juggling Granny*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by/4.0/
Contributing translators: Solyda Say and Nhean Socheat